ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១៤០

ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩

សាលដីកា

លេខ: ១៣ "I"

ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធានអង្គជំនុំជម្រះ

២.លោក [redacted] ចៅក្រមរបាយការណ៍

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើពាក្យបណ្ដឹងសាទុក្ខលេខ ១៦៨ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted] ដុនធី និង លោក [redacted] សុគន់ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៣០ ក្រ.VI "ប.ស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ដែលមាន ៖

-ជនជាប់ចោទឈ្មោះ [redacted] សុខា ភេទស្រី អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មការិនីរោងចក្រ ទីកន្លែងកំណើតនៅភូមិអូរស្វាយចេក ឃុំរការក្នុង ស្រុកទ្រាំងខេត្ត ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នមុនពេលឃុំខ្លួន [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" ប្ដីឈ្មោះ [redacted] (លែងលះ) មានកូន ០២នាក់ ទោសពីមុនគ្មាន (ក្នុងឃុំ) ។ (អ្នកប្ដឹងសាទុក្ខ)



Scanned with CamScanner

លោក [redacted] សុគន់ និងលោក [redacted] ដុនធី ជាមេធាវីការពារសិទ្ធិ ។

**ជាប់ចោទពីបទ ៖** ជេរប្រមាថជាសាធារណៈ និងញុះញង់ឱ្យមានការរើសអើង ប្រព្រឹត្តនៅប្រទេសថៃ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៧ មាត្រា ៤៩៤ និងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌ ។

**អំពីអង្គហេតុ ៖**

កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅប្រទេសថៃ មានករណីជេរប្រមាថជាសាធារណៈ និងញុះញង់ឱ្យមានការរើសអើងមួយបានកើតឡើងដោយជនជាប់ចោទឈ្មោះ [redacted] សុខា ពិតប្រាកដមែន ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១០ "ខ" ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុខា ភេទស្រី អាយុ៣៩ឆ្នាំ(ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២ឆ្នាំ ដោយអនុវត្តបន្តពីសាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ជ" ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ស្ពឺ និងពិន័យជាប្រាក់ចំនួន ៥.០០០.០០០(ប្រាំលាន)រៀល ពីបទ ជេរប្រមាថជាសាធារណៈ និងញុះញង់ឱ្យមានការរើសអើង ប្រព្រឹត្តនៅប្រទេសថៃ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៧ តាមមាត្រា ៣០៧ មាត្រា ៤៩៤ និងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខា ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុខា ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១០ "ខ" ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៣០ ក្រ.VI "ប.ស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុខា ទុកជាត្រឹមត្រូវតាមច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០ "ខ" ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការដដែល ។



Scanned with CamScanner

៣.បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធីច្បាប់ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]សុខា និងប្រកាសជាសាធារណៈ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ។

បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ១៦៨ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted]ដុនធី និងលោក [redacted]សុគន់ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សុខា ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៣០ ក្រ.VI "ប.ស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

**នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋានសុំថា ៖

-យល់ឃើញថា បណ្ដឹងសាទុក្ខរបស់លោក [redacted]ដុនធី និងឈ្មោះ [redacted]សុគន់ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ[redacted]សុខា មិនមានមូលហេតុដូចក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។ ហើយតុលាការអង្គសេចក្ដីបានបញ្ជាក់អំពីការយល់ឃើញរបស់ខ្លួន ។

ដូចនេះ តំណាងមហាអយ្យការយល់ស្របតាមការលើកឡើងរបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទាំងស្រុង ។

ហេតុដូច្នេះ

តំណាងមហាអយ្យការប្ដឹងសុំចំពោះតុលាការកំពូលឱ្យ

១.ទទួលបណ្ដឹងសាទុក្ខលេខ ១៦៨ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted]ដុនធី និងឈ្មោះ [redacted]សុគន់ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សុខា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសទៅនឹងគតិច្បាប់ ។

២.តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣០ ក្រ.VI "ប.ស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

+ជនជាប់ចោទឈ្មោះ [redacted]សុខា បានឆ្លើយថា ៖ នាងខ្ញុំមានអាយុ៣៦ឆ្នាំ មុខរបរកម្មកររោងចក្រ មុនពេលចាប់ខ្លួននៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានកូន ០២នាក់ ប្រុស ០១ ស្រី ០១ ។ នាងខ្ញុំប្ដឹងសាទុក្ខមកនេះមូលហេតុពាក់ព័ន្ធនឹងសំណាង ៥.០០០.០០០(ប្រាំលាន)រៀល នាងខ្ញុំគ្មានលទ្ធភាពសងគេទេ នាងខ្ញុំមានការ



Scanned with CamScanner

ឈឺចាប់បាត់បង់ការងារ ឪពុកក៏ស្លាប់ ទើបនាងខ្ញុំមានបញ្ហាមួរម៉ៅ ក៏ប្រើទូរស័ព្ទបង្ហោះហ្វេសប៊ុក ដោយប្រើទូរស័ព្ទបង្កើតអាខោន ហើយបញ្ហាបង្កើតអាខោននេះ គឺគេបង្កើតឱ្យនាងខ្ញុំ ក្នុងរឿងនេះនាងខ្ញុំសុំទទួលស្គាល់ក្នុងការជេរប្រមាថ ហើយនាងខ្ញុំក៏ធ្វើការសុំទោសថ្នាក់ដឹកនាំដែរ ។

សំណូមពរ ៖ សុំឱ្យលើកលែងនាងខ្ញុំ ដើម្បីមើលម្តាយចាស់ជរា និងសុំលើកលែងប្រាក់ពិន័យ ។

+ លោក [redacted] ដុនធី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខា បានធ្វើសេចក្តីសន្និដ្ឋាន ថា ៖ អ្នកស្រី [redacted] សុខា ត្រូវបានតុលាការផ្តន្ទាទោសនូវបទល្មើសប្រហាក់ប្រហែលគ្នាដល់ទៅពីរសាលក្រម ពី បទជេរប្រមាថ និងធ្វើឱ្យមានការរើសអើង ។ តាមគោលការណ៍ច្បាប់ មានបទល្មើស ទាល់តែមានច្បាប់ចែង (មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ) និងមានចេតនាច្បាស់លាស់ទេ ត្រូវផ្តន្ទាទោស(មាត្រា ៤ នៃក្រមដដែល) ។ អ្នកស្រី [redacted] សុខា មិនយល់ច្បាស់ពីប្រព័ន្ធបច្ចេកវិទ្យាដូចជា ហ្វេសប៊ុកនេះ ដំណើរការយ៉ាងណាច្បាស់លាស់ទេ ។ យ៉ាងណាមិញ ច្បាប់ក៏ពុំចែងពីប្រព័ន្ធបច្ចេកវិទ្យានេះច្បាស់លាស់នៅឡើយដែរ ដូច្នេះ អ្នកស្រី [redacted] សុខា គួរតែមិនត្រូវបានចោទប្រកាន់ឡើយ ។ ច្បាប់ចែងថា "ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។" ចំណុចទី៣ នៃមាត្រា ៤៩៤ លក្ខខណ្ឌអត្ថិភាពនៃការញុះញង់ និងមាត្រា ៣០៧ ជេរប្រមាថជាសាធារណៈ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ ។ ដូច្នេះ ច្បាប់កំណត់អំពើល្មើសទាំងឡាយណាផ្សាយតាមរយៈទូរគមនាគមន៍សោតទស្សន៍ ប៉ុណ្ណោះ ។ អ្នកស្រី [redacted] សុខា ពិតជាមានវិបត្តិក្នុងគ្រួសារធ្វើឱ្យស្មារតីក៏មិនប្រសើរដែរ ចេះតែធ្វើអ្វីតាមកំហឹងចេញពីវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ ។ អ្នកស្រី [redacted] សុខា បានដាក់ស្នើសុំពីការយល់យោគពីសំណាក់ថ្នាក់ដឹកនាំ មួយលើក ជាពីរលើកមកហើយដែរ ។ តាមលោកតំណាងមហាអយ្យការនៅពេលសវនាការសាលាឧទ្ធរណ៍ ក៏បានលើកឡើងពីអង្គហេតុប៉ះពាល់ដល់បុគ្គលសាធារណៈបែបនេះ គួរតែសន្តោសដល់អ្នកស្រី [redacted] សុខា ដោយសារគាត់បានទទួលរងការផ្តន្ទាទោសមួយមុនរួចហើយពីបទដូចគ្នានេះ ។ សាលាឧទ្ធរណ៍ពុំបានពិចារណាតាមអង្គហេតុ និងអង្គច្បាប់ ដែលតំណាងមហាអយ្យការ កូនក្តី និងខ្ញុំបាទលើកឡើងឡើយ ទើបប្តឹងសាទុក្ខមកនេះ ។

ដោយផ្អែកតាមអង្គហេតុខាងលើ អ្នកស្រី [redacted] សុខា ជាជនរងគ្រោះពីប្រព័ន្ធបច្ចេកវិទ្យា ហើយមានវិបត្តិធ្ងន់ធ្ងរក្នុងគ្រួសារផង តែអ្នកស្រីបានស្នើសុំអភ័យទោសដល់ថ្នាក់ដឹកនាំរួចហើយ ។ ដោយផ្អែកតាមអង្គច្បាប់នៅមិនទាន់មានចែងច្បាស់លាស់ពីទំនាក់ទំនងតាមប្រព័ន្ធបច្ចេកវិទ្យានេះ ជាបទល្មើសច្បាស់នៅឡើយដែរ ។

សំណូមពរ ៖ សូមអង្គជំនុំជម្រះតុលាការកំពូល មេត្តាផ្តល់យុត្តិធម៌ដល់អ្នកស្រី [redacted] សុខា ដោយសម្រេចឱ្យគាត់រួចផុតពីបទចោទនេះ ។



Scanned with CamScanner

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៦៨ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted]សុខា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា នាពេលសវនាការនៅតុលាការកំពូលនេះ ជនជាប់ចោទក៏ដូចជាមេធាវីការពារសិទ្ធិជនជាប់ចោទដែរ បានសុំឱ្យតុលាការសម្រេចប្រកាសទោសឱ្យកូនក្តីខ្លួនឱ្យអនុវត្តទោសស្រូបបញ្ចូលគ្នាទាំងមូលនៃទោសដែលមានប្រភេទដូចគ្នា តាមស្មារតីមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ ដោយសំអាងហេតុថា កូនក្តីខ្លួនត្រូវបានសាលាដំបូងខេត្តកំពង់ស្ពឺ សម្រេចសេចក្តីតាមសាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ជ" ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥.០០០.០០០(ប្រាំលាន)រៀល ចូលថវិកាជាតិ ពីបទ ញុះញង់ឱ្យមានការរើសអើង និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅចំណុចផ្លូវលេខ៤៥ ចន្លោះគីឡូម៉ែត្រលេខ ៤-៥ ស្ថិតនៅភូមិអុង ឃុំចាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៣០៧ មាត្រា ៤៩៤ និងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ម្តងរួចហើយ១ បច្ចុប្បន្នកូនក្តីរបស់ខ្លួនត្រូវបានតុលាការសម្រេចចោទប្រកាន់ និងផ្តន្ទាទោស ពីបទល្មើសជេរប្រមាថជាសាធារណៈ និងញុះញង់ឱ្យមានការរើសអើង ប្រព្រឹត្តនៅប្រទេសថៃ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៣០៧ មាត្រា ៤៩៤ និងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌ ដោយសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ ដោយអនុវត្តបន្តពីសាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ជ" ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ស្ពឺ និងពិន័យជាប្រាក់ចំនួន ៥.០០០.០០០(ប្រាំលាន)រៀល ហើយម្យ៉ាងវិញទៀត កូនក្តីខ្លួនបានទទួលស្គាល់នូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តបទល្មើស ព្រមទាំងបានធ្វើលិខិតជាផ្លូវការសុំទោសដល់ប្រមុខរាជរដ្ឋាភិបាលទៀតផងនោះ តុលាការកំពូលពិនិត្យលើនីតិវិធីបណ្តឹងនៃសំណុំរឿងព្រហ្មទណ្ឌ ៣៨៣ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ដែលមានសាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ជ" ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ស្ពឺត្រូវបានប្តឹងឧទ្ធរណ៍ ហើយប្រធានសាលាដំបូងខេត្តកំពង់ស្ពឺបានបញ្ជូនមកសាលាឧទ្ធរណ៍ នៅថ្ងៃទី០៣ ខែមេសា



Scanned with CamScanner

ឆ្នាំ២០១៨ ដូច្នេះ តុលាការកំពូលមិនមែនជាតុលាការចុងក្រោយដែលអាចសម្រេចបញ្ចូលទោស ដូចមានកំណត់ក្នុងមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌបានទេ ។ ម្យ៉ាងទៀត ជនជាប់ចោទ ក៏ដូចជាមេធាវីរបស់ខ្លួនដែរ មិនបានលើកឡើងនូវការជំទាស់ណាមួយចំពោះសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ក្រៅពីការស្នើសុំឱ្យស្រូបទោសបញ្ចូលគ្នា នោះ តុលាការកំពូលមិនចាំបាច់ពិចារណាបន្ថែមទៀតទេ ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ មិនមានមូលហេតុដូចមានកំណត់តាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៣០ ក្រ.VI "ប.ស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ដែលសម្រេចមកនេះ ត្រឹមត្រូវតាមគតិច្បាប់ ។

## ហេតុដូច្នេះ
## សម្រេច

១.បដិសេធ បណ្តឹងសាទុក្ខលេខ ១៦៨ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុខា ។

២.តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ៣០ ក្រ.VI "ប.ស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ទាំងមូល ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner